# សេចក្តីថ្លែងការណ៍ស្តីពី ស្ថានភាពនៃការបញ្ជូនពលករខ្មែរចំណាកស្រុកមកពីប្រទេសថៃ



សមាគម ការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជាហៅកាត់ថា (អាដហុក) សូមសំដែងនូវការខកចិត្តជាខ្លាំងពីរបៀបនៃការបញ្ជូនពលករចំណាកស្រុក ខ្មែរចេញពីប្រទេសថៃដែលពុំមានលក្ខណៈស៊ីវិល័យអមនុស្សធម៌ដែលនាំ ឲ្យមានការរំលោភដ៏ធ្ងន់ធ្ងរដល់សិទ្ធិរបស់ពលករចំណាកស្រុកទាំងនោះ។

របៀបបណ្តេញពលករចំណាកស្រុកពីប្រទេសថៃនេះ ធ្វើឡើងដោយការបំភិតបំភ័យពីអាជ្ញាធរយោធាថៃ ធ្វើឲ្យមានការតក់ស្លុតជាខ្លាំងដល់ស្មារតីរបស់ពលករចំណាកស្រុក ជាទូទៅ។ វិធីដែលធ្វើឲ្យមានការតក់ស្លុតជាខ្លាំងនេះគឺពលករចំណាកស្រុកពិត ជាបានទទួលការគំរាកកំហែង មបំបាក់ស្មារតី បំភិតបំភ័យ ធ្វើទារុណកម្ម និងការប្រើអំពើហិង្សា ផ្សេងៗទៀតដែលនាំឲ្យប៉ះពាល់ដល់អាយុជីវិតពលករកម្ពុជាមួយចំនួន។ យើងបាន សំភាសសាក្សីឃើញផ្ទាល់ភ្នែក ដែលបានបញ្ជាក់ពីមូលហេតុដែលធ្វើឲ្យមានឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរណ៍ រហូតមានការស្លាប់នេះ គឺដោយសារការបាញ់សម្លុតគំរាមកំហែងពីយោធាថៃនេះឯង។ សាក្សីខ្លះទៀតបានឃើញហេតុការណ៍នៃការបាញ់សម្លាប់ពីយោធាថៃមកលើពលករ ចំណាកស្រុកខ្លះដែលព្យាយាមគេចពីការចាប់ខ្លួនពួកគេ។ ក្រៅពីនេះពលករខ្មែរចំណាកស្រុកមួយចំនួនទៀតត្រូវបានទទួលរងនូវការ ដកហូតប្រាក់កាសតាមទំនើងចិត្ត ហើយចាប់បញ្ជូនមកកម្ពុជាវិញដូចសត្វធាតុ។



សមាគម អាដហុកមានការសោកស្តាយជាខ្លាំងដែលប្រទេសទាំង ១០ ក្នុងតំបន់អាស៊ីអាគ្នេយ៍កំពុងតែត្រៀមចូលជា «សហគមន៍តែមួយ និងមានវាសនាតែមួយ» នៅឆ្នាំ ២០១៥ ខាងមុខ បែរជាមានរដ្ឋជាសមាជិកអាស៊ានមួយរំលោភសិទ្ធិយ៉ាងធ្ងន់ធ្ងរទៅប្រជាជននៃរដ្ឋផ្សេងទៀតនៃសហគមន៍អាស៊ានបែបនេះ។ យើងសូមសួរថា៖ តើប្រជាជនក្រីក្រក្នុងប្រទេសជាសមាជិកអាស៊ាន មិនមែនជាប្រជាជនអាស៊ានទេឬ ម្តេចបានជាប្រមាថកាតទានពលករក្រីក្រក្នុងប្រទេសអាស៊ានបែបនេះ? ព្រោះថាបើចាត់ទុកប្រជាជននៃប្រទេសនានាក្នុងអាស៊ានជាប្រជាជនអាស៊ាន ដូចគ្នា រដ្ឋជាសមាជិកអាស៊ានគួរតែមានវិធានការដែលមានលក្ខណៈស៊ីវិល័យ គោរពសិទ្ធិមនុស្ស គោរពកិត្តិយស និងសេចក្តីថ្លៃថ្នូ និងគោរពស្មារតីនៃធម្មនុញ្ញអាស៊ានទៅលើពលករដែលមកពីប្រទេសអាស៊ាន ដូចគ្នា។



យើងយល់ ថារដ្ឋអំណាចឃោធាថៃមានសិទ្ធិក្នុងការបណ្ដេញចេញនូវពលករចំណាកស្រុក ដែលពុំមានឯកសារស្របច្បាប់ តែគួរធ្វើឡើងតាមវិធីដែលមានលក្ខណៈមនុស្សធម៌ គោរពសិទ្ធិ និងសេចក្ដីថ្លៃថ្នូររបស់ពលករកម្ពុជា ដោយធ្វើសេចក្ដីប្រកាសជាទូទៅដល់ពលករចំណាកស្រុកពុំមានឯកសារ ស្របច្បាប់ឲ្យធ្វើការចាកចេញដោយស្ម័គ្រចិត្តក្នុងថេរវេលាសមស្រប មួយជាកំណត់សិន។ នៅពេលហួសកាលកំណត់នេះ បើពលករណាពុំព្រមចាកចេញ សឹមធ្វើការចាប់ខ្លួន ផាកពិន័យ ឬបញ្ជូនខ្លួនមកប្រទេសដើមរបស់ខ្លួនវិញ។ ទន្ទឹមនឹងនេះរដ្ឋអំណាចឃោធាថៃគួរតែធ្វើកិច្ចសហការជាមួយនឹងរដ្ឋាភិ បាលដែលមានពលករនៅក្នុងប្រទេសខ្លួនឲ្យត្រៀមរៀបចំទទួលពលករដែលបញ្ជូន ចេញនេះឲ្យបានត្រឹមត្រូវ។

ដើម្បីដោះស្រាយនូវបញ្ហាខាងលើឲ្យបានត្រឹមត្រូវតាមស្មារតី នៃធម្មនុញ្ញអាស៊ាន «សហគមន៍តែមួយ វាសនាតែមួយ» និងអនុលោមតាមគោលការណ៍សិទ្ធិមនុស្សជាសកលៈ

- ប្រទេសទទួលពលករចំណាកស្រុកគួរតែបង្កលក្ខណៈ ងាយស្រួលក្នុងការផ្ដល់សិទ្ធិធ្វើការងារស្របច្បាប់ឲ្យបានច្រើនតាម តម្រូវការនៃទីផ្សារការងាររបស់ខ្លួន។ មិនត្រូវបណ្ដេញពលករចំណាកស្រុកដូចដែលបានធ្វើរួចមកហើយនេះទៀតទេ។
- ប្រទេសបញ្ជូនពលករចំណាកស្រុក (រាជរដ្ឋាភិបាលកម្ពុជាជាដើម) គួរតែមានវិធានការបង្កើតការងារសំរាប់ប្រជាជនរបស់ខ្លួនឲ្យបាន ជាអតិបរិមាដើម្បីកាត់បន្ថយការធ្វើចំណាកស្រុក។
- រាជរដ្ឋាភិបាលកម្ពុជាគួរតែមានវិធានការផ្ដល់លំនៅដ្ឋាន និងដីធ្លីឲ្យបានគ្រប់គ្រាន់ជូនដល់ពលករដែលត្រឡប់មកប្រទេសវិញដែល ពុំមានលំនៅដ្ឋាន និងដីធ្លីសំរាប់ចិញ្ចឹមជីវិត។
- អាស៊ានគួរតែជំរុញឲ្យបានឆាប់ក្នុងការបង្កើត គណៈកម្មការអាស៊ានពីសិទ្ធិពលករចំណាកស្រុក ដើម្បីជួយការពារ និងលើកស្ទួយដល់សិទ្ធិរបស់ពលករចំណាកស្រុកក្នុងតំបន់អាស៊ាន។

***<u>សំរាប់ព័ត៌មានលំអិតសូមទាក់ទងៈ</u>***

*- លោក ធន សារាយ ប្រធានសមាគមអាដហុក ០១៦ ៨៤ ០០ ៨៤ ភាសារខ្មែរ អង់គ្លេស និងបារាំង*

*- លោក នី ចរិយា ប្រធានផ្នែកសិទ្ធិមនុស្ស និងជំនួយផ្លូវច្បាប់ ០១១ ២៧ ៤៩ ៥៩ ភាសារខ្មែរ អង់គ្លេស*

*- អ្នកស្រី ឆន សុគន្ធា ប្រធានផ្នែកស្ត្រី កុមារ និងដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ ០១២ ៣៨៤ ៧១៩ ភាសារខ្មែរ និងអង់គ្លេស*